**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

# កំណត់ហេតុស្តីពីការប្រជុំពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ សម្រាប់ការិយបរិច្ឆេទ២០២២

ឆ្នាំពីរពាន់ម្ភៃបួន ខែកញ្ញា ថ្ងៃទីបួន វេលាម៉ោងបីរសៀល ប្រតិភូសវនកម្មផ្ទៃក្នុងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយ លោក **យួន សុជាតិ** បានជួបប្រជុំគ្នាជាមួយថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ ដើម្បីពិភាក្សាលើលទ្ធផលនៃការកែលម្អលើការងារដែលប្រតិភូសវនករបានពិនិត្យកន្លងមក។ សមាសភាពចូលរួមមានដូចខាងក្រោម:

**ក-<u>សមាសភាពប្រតិភូសវនកម្មផ្ទៃក្នុង</u>**

១-លោក **យួន សុជាតិ** ប្រធានប្រតិភូ

២-លោក **គុន ចិន្តាមណី** អនុប្រធានប្រតិភូ

៣-លោក **ហេង វាសនា** សមាជិក

៤-លោក **ជា សីខ្ហុធ** សមាជិក

៥-លោក **នី ម៉ាល័យ** សមាជិក

៦-លោក **អេ ប៊ុនថេត** សមាជិក

**ខ- <u>សមាសភាពថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ</u>**

១-លោក **សំ សារឿន** ប្រធានមន្ទីរ

២-លោក **ទិញ វិណ្ណ** ប្រធានការិយាល័យរដ្ឋបាល

៣-លោក **សួស គីមសឿន** ប្រធានការិយាល័យសំណង់

៤-លោក **ស៊ិង សីលា** អនុប្រធានការិយាល័យរដ្ឋបាល

ជាកិច្ចចាប់ផ្តើម លោក **សំ សារឿន** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ បានសំដែងនូវភាពសោមនស្សដល់ប្រតិភូសវនករនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះមកតាមដានអនុសាសន៍ដែលបានផ្តល់ឱ្យកន្លងមកដល់មន្ទីរ សម្រាប់ធ្វើការកែលម្អ និងថ្លែង

អំណរគុណចំពោះលទ្ធផលសវនកម្មដែលសម្រេចបាន។ បន្ទាប់មក លោកប្រធានមន្ទីរ បានប្រគល់នាទីជូនលោកប្រធានប្រតិភូសវនកម្មមានមតិបើកអង្គប្រជុំ÷

លោក **ឃួន សុជាតិ** ប្រធានប្រតិភូ និងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង បានជម្រាបជូនអង្គប្រជុំថា ការចុះមកពេលនេះដោយយោងលិខិតបញ្ជាបេសកកម្មលេខ១៣៧ និងលេខ១៣៩ ដនស ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យពីការកែលម្អតាមអនុសាសន៍ បានចុះធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២២ និងបណ្ដាឆ្នាំពាក់ព័ន្ធដែលបានផ្ដល់អនុសាសន៍ដូចខាងក្រោម÷

**ក.អនុសាសន៍របស់សវនកម្មផ្ទៃក្នុង÷**

១. មន្ទីរត្រូវខិតខំជំរុញបន្ថែមទៀត និងពន្យល់ណែនាំឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុនធ្វើការសាងសង់ និងលិខិតបិទការដ្ឋាននៅពេលសំណង់សាងសង់ហើយ។

២. មន្ទីរត្រូវរៀបចំកន្លែងបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) ដែលមានដាក់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដី និងភូមិសាស្ត្រឱ្យបានឆាប់រហ័ស។

**ខ.វិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១-រាល់វិក្កយបត្រទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន ត្រូវចុះលេខ និងមានប្រភពច្បាស់លាស់ ស្របតាមប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

២-រាល់ការចុះបំពេញបេសកកម្ម ត្រូវមានរបាយការណ៍លទ្ធផលបេសកកម្មភ្ជាប់ឱ្យបានត្រឹមត្រូវស្របតាមប្រកាសលេខ ០៩៩ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្ដីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្ម ក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

៣-រាល់កិច្ចសន្យាកិច្ចលទ្ធកម្ម ត្រូវមានហត្ថលេខាខ្ទីពីគ្រប់ភាគីពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ស្របតាមសារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

៤-ការប្រើប្រាស់ប្រេងឥន្ធនៈ សម្ភារការិយាល័យ ត្រូវមានបញ្ជីតាមដានសន្និធិឱ្យត្រឹមត្រូវស្របតាម វិធីគ្រប់គ្រងសន្និធិឃ្លាំង។

**គ.ផែនការការកែលម្អរបស់អគ្គនាយកលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១. ឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យា និងបញ្ជីប៉ាន់តម្លៃសម្ភារៈមិនបានបញ្ជាក់ប្រភព។

២. អ្នកម្ចាស់ការមិនបានចេញលិខិតបញ្ជាក់ការបញ្ចប់ការងារសំណង់។

បន្ទាប់មក លោកប្រធានមន្ទីរ និងមន្ត្រីជំនាញពាក់ព័ន្ធមានមតិបំភ្លឺ និងបង្ហាញឯកសារដើម្បីបញ្ជាក់ពីការកែលម្អតាមអនុសាសន៍លើកឡើងខាងលើ។ ជាលទ្ធផល ប្រតិភូសវនករ និងអង្គភាពសវនដ្ឋានបានពិនិត្យ ព្រមទាំងឯកភាពគ្នាដូចតទៅ÷

**ក. ការឆ្លើយតបចំពោះអនុសាសន៍សវនកម្មផ្ទៃក្នុង÷**

១. មន្ទីរបានឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាននៅក្នុងឆ្នាំ២០២៣ បានល្អប្រសើរ ដោយក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ មានលិខិតអនុញ្ញាតសាងសង់ចំនួន១២ គម្រោង ហើយលិខិតបើកការដ្ឋានមានចំនួន០៩ គម្រោង ចំពោះលិខិតអនុញ្ញាតបិទការដ្ឋានសាងសង់មន្ទីរនឹងឱ្យម្ចាស់សំណង់មកស្នើសុំលិខិតបិទការដ្ឋាននៅពេលបញ្ចប់ការសាងសង់។

២. មន្ទីរបាននឹងកំពុងជួសជុល ពង្រីកបន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលមានដាក់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដី និងភូមិសាស្ត្រ ក្រោយការបញ្ចប់មន្ទីរនឹងរៀបចំកន្លែងបំពាក់ប្រព័ន្ធការពារអគ្គីភ័យ។

**ខ. ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១- មន្ទីរនឹងអនុវត្តវិក្កយបត្រទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន ឱ្យស្របតាមប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ចំពោះបច្ចុប្បន្នមន្ទីរអនុវត្តពុំទាន់បានដោយសារការទិញសម្ភារៈតាមរជ្ជទេយ្យពីកន្លែងទិញទំនិញ វិក្កយបត្ររបស់គាត់ពុំមានលេខ និងអាសយដ្ឋានច្បាស់លាស់។

២- មន្ទីរនឹងតម្រូវឱ្យមានរបាយការណ៍លទ្ធផលការងារចុះបេសកកម្មឱ្យស្របតាមប្រកាសលេខ០៩៩ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្ម ក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ ឱ្យបានគ្រប់ចំនួន។

៣- រាល់កិច្ចសន្យាកិច្ចលទ្ធកម្ម មន្ទីរបានចុះហត្ថលេខាខ្ទីពីគ្រប់ភាគីពាក់ព័ន្ធរួចហើយ។

៤- ការប្រើប្រាស់ប្រេងឥន្ធនៈ សម្ភារការិយាល័យ មន្ទីរនឹងរៀបចំធ្វើបញ្ជីតាមដានសន្និធិឱ្យស្របតាមវិធីគ្រប់គ្រងសន្និធិឃ្លាំង។

**គ. ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គនាយកលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១. មន្ទីរបានធ្វើឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យា និងបញ្ជីប៉ាន់តម្លៃសម្ភារៈបានបញ្ជាក់ប្រភពរួចហើយ។

២. ក្នុងឆ្នាំ២០២៣មន្ទីរបានចេញវិញ្ញាបនបត្របញ្ចប់ការងារសំណង់តាមលិខិតលេខ០៣៤ ដនសស/ពហ/កល ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣។

ប្រតិភូសវនករបានទទួលយកនូវមតិឆ្លើយតបរបស់សវនដ្ឋាន និងបានជម្រាបជូនសវនដ្ឋានថា ប្រតិភូសវនករនឹងត្រូវរៀបចំរបាយការណ៍ស្តីពីការកែលម្អតាមអនុសាសន៍ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ជ្រាបជារបាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

ជាទីបញ្ចប់ លោកប្រធានមន្ទីរ បានថ្លែងអំណរគុណចំពោះលទ្ធផលការងាររបស់ប្រតិភូ ហើយនឹងបន្តអនុវត្តការងារដែលនៅសេសសល់។

កិច្ចប្រជុំរវាងប្រតិភូសវនកម្មផ្ទៃក្នុង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ បានចប់សព្វគ្រប់នៅវេលាម៉ោងប្រាំ និងសាមសិបនាទីល្ងាច នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសជាភាតរៈ និងស្មារតីទទួលខុសត្រូវខ្ពស់។

**ប្រធានមន្ទីរ**

សំ សារឿន

**ប្រធានប្រតិភូ**

ឃួន_សុជាតិ

# ឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធទី ១ - ការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សវនដ្ឋាន : មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ

របាយការណ៍សវនកម្ម:លេខ០៤៤ របក/សផក — កាលបរិច្ឆេទបញ្ចប់របាយការណ៍ស្ថាពរ: ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣

*អាទិភាព (ប្រសិនមាន)

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាតងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់សម្រាប់ពង្រឹងប្រព័ន្ធ និងនីតិវិធី។
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ ឬចងក្រងឯកសារក្នុងទីកន្លែងដែលមិនសូវសំខាន់។

*វិធានការដែលត្រូវអនុវត្តដោយថ្នាក់ដឹកនាំ

*អព: បានអនុវត្តតាមអនុសាសន៍ពេញលេញ និងបានកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន។

*អខ: បានអនុវត្តតាមអនុសាសន៍ខ្លះ និងហានិភ័យសំណល់ស្ថិតក្នុងកម្រិតមួយមិនអាចទទួលយកបាន។

*មអ: មិនបានអនុវត្តតាមអនុសាសន៍ និងហានិភ័យនៅតែមាន។

*មព: មិនមានហានិភ័យពាក់ព័ន្ធ និងមិនមានហានិភ័យសំណល់ទៀតទេ។

| លេខអនុសាសន៍ | អនុសាសន៍សវនកម្ម | *អាទិភាព (សូមមើល ខ្ពស់/ មធ្យម/ ទាប) | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពអនុវត្ត | កាលបរិច្ឆេទតាមដាន | វិធានការដោយថ្នាក់ដឹកនាំ (សូមមើល ខាងលើ) | ភស្តុតាងនៃការអនុវត្តដោយថ្នាក់ដឹកនាំ ឬកាលបរិច្ឆេទត្រូវកែសម្រួល និងឯកភាពជាមួយថ្នាក់ដឹកនាំសម្រាប់ការអនុវត្តបន្ត។ |
|---|---|---|---|---|---|---|---|
| ១ | មន្ទីរ ត្រូវខិតខំជំរុញបន្ថែមទៀត និងពន្យល់ណែនាំឱ្យមកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុនធ្វើការសាងសង់ និងលិខិតបិទការដ្ឋាននៅពេលសំណង់សាងសង់ហើយ។ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បាននិងកំពុងអនុវត្ត |
| ២ | មន្ទីរ ត្រូវរៀបចំកន្លែងបំពាក់ប្រព័ន្ធការពារអគ្គិភ័យ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បាននឹងកំពុងអនុវត្ត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នៅក្នុងបន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលមានដាក់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដី និងភូមិសាស្ត្រឱ្យបានឆាប់រហ័ស។ | | | | | | |

រៀបចំដោយៈ លោក **នី ម៉ាល័យ** កាលបរិច្ឆេទៈ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤

ត្រួតពិនិត្យដោយៈ លោក **ហេង វាសនា** កាលបរិច្ឆេទៈ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤

ខេត្តព្រះវិហារ, ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤

**ប្រធានមន្ទីរ**

សំ សារឿន

## ២. ឧបសម្ព័ន្ធទី ២ - ផែនការសកម្មភាពកែលម្អ

របាយការណ៍ ៖ សវនកម្មនៅ **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ ការិយបរិច្ឆេទ២០២២**

របាយការណ៍លេខ: ....០៤៤..... /របក ចុះថ្ងៃទី.....០៤..... ខែ...ឧសភា... ឆ្នាំ២០២៣

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាត ងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់ពង្រឹងប្រព័ន្ធ និងនីតិវិធី
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ឬចងក្រងឯកសារក្នុងទីដែល មិនសូវសំខាន់
- អ.ព: អនុវត្តតាមអនុសាសន៍ឱ្យបានពេញលេញ និងកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន ។

| អនុសាសន៍លេខ | សកម្មភាពដែលថ្នាក់ដឹកនាំបានឯកភាព | អាទិភាព* | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពបញ្ចប់ការអនុវត្ត |
|---|---|---|---|---|
| **១. ផ្នែកអនុលោមភាព** | | | | |
| ក. មន្ទីរ ត្រូវខិតខំជំរុញបន្ថែមទៀត និងពន្យល់ណែនាំឱ្យមកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានមុនធ្វើការសាងសង់ និងលិខិតបិទការដ្ឋាននៅពេលសំណង់សាងសង់ហើយ។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរ នឹងជំរុញឱ្យម្ចាស់សំណង់ ស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន និងបិទការដ្ឋាននៅពេលសំណង់រួចរាល់។ |

| | | | | |
|---|---|---|---|---|
| **ខ.មន្ទីរ** ត្រូវរៀបចំកន្លែងបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលមានដាក់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដី និងភូមិសាស្ត្រឱ្យបានឆាប់រហ័ស។ | អ.ព | មធ្យម | ប្រធានមន្ទីរ | **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ** និងរៀបចំបំពាក់ប្រព័ន្ធការពារអគ្គីភ័យក្នុងបន្ទប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលមានដាក់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកដាក់ឯកសារសុរិយោដី និងភូមិសាស្ត្រ។ |

**ប្រធានមន្ទីរ**

**សំ សារឿន**

**ប្រតិភូសវនករ**

**យួន-សុជាតិ**